# ការសំភាស៍របស់លោកពូ ចឹង ចាន់ថា

កៈ អ្នកដែលសំភាស៍គេ សួន សុខលី        ខៈ អ្នកដែលត្រូវបានគេសំភាស៍ ចឹង ចាន់ថា

កៈ ចឹងអរជាដំបូងខ្ញុំសូមថ្លែងអំណរគុណដល់លោកពូដែលអោយខ្ញុំ
ធ្វើការសំភាស៍អំពីជីវប្រវិត្តរបស់លោកពូណា។
ហើយការសំភាស៍មួយនេះគឺធ្វើឡើងនៅដោយសារតែ សកលវិទ្យាល័យ BYU
ហើយដោយសារតែសកលវិទ្យាល័យនិងចង់ថែរក្សាជីវប្រវិត្តជីដូនជីតារបស់លោកពូ
ហើយទុក្ខអោយកូនចៅជំនាន់ក្រោយរបស់លោកពូនិងស្តាប់មើលបន្តាប់ពីការសំភាស៍នេះរួ
ចហើយ។
ចឹងខ្ញុំចង់សួរលោកពូថាបន្ទាប់ពីការសំភាស៍នេះរួចតើខ្ញុំអាចសុំដាក់ការសំភាស៍មួយនិងនៅ
ក្នុងប្រព័ន្ធវិបផ្សាយមួយដែលមានឈ្មោះថា WWW. Cambodianoralhistories.byu.edu
បានដែលឬទេលោកពូ?

ខៈ បានតាស់ អត់អីទេ។

កៈ ចាចឹងការសំភាស៍មួយនិងគឺធ្វើឡើងនៅថ្ងៃទីអើ ២០ ខែ០១ ឆ្នាំ២០១៨
ហើយការសំភាស៍មួយនេះគឺមានទីតាំងនៅអើ ភូមិបួន សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ។

កៈ ចឹងខ្ញុំចង់សួរលោកពូថា តើលោកពូមានឈ្មោះអីគេដែលលោកពូ?

ខៈ ខ្ញុំមានឈ្មោះថា ចឹងចាន់ថា។

កៈ ចឹង ចាន់ថា។

ខៈ បាទ។

កៈ
ចឹងឈ្មោះរបស់លោកពូនិងតើត្រូវជាមួយនិងអតសញ្ញាណប័ណ្ណរបស់លោកពូដែលឬទេ
លោកពូ?

ខ៖ បាទត្រូវទាំងអស់។

ក៖ ចាចឹងខ្ញុំចង់សួរលោកពូថា
លោកពូមានឈ្មោះហៅក្រៅឬក៏មាននាមអីដែលគេហៅក្រៅតាំងតែអីតូចមកទេលោកពូ?

ខ៖ អត់មានទេឈ្មោះតែមួយនិងទេ។

ក៖ ចាចឹងគេហៅតែលោកពូ ឈ្មោះតែមួយចឹងតែម្តង?

ខ៖ បាទ។

ក៖ ចាចឹងខ្ញុំចង់សួរលោកពូទៀតថា អើតើលោកពូឥឡូវមានអាយុប៉ុន្នានហើយ?

ខ៖ ខ្ញុំឥឡូវមានអាយុហាសិបបីរឆ្នាំហើយ។

ក៖ ហារសិបបីរឆ្នាំហើយ។ ចុះលោកពូកើតនៅឆ្នាំណាថ្ងៃណា
ហើយនៅកន្លែងណាដែលលោកពូ?

ខ៖ ខ្ញុំកើតនៅស្រុកកំណើត ខ្ញុំកើតនៅកំពង់ចាម។

ក៖ កំពង់ចាម ស្រុកអីគេ ឃុំអីគេដែលលោកពូ?

ខ៖ ខេត្តកំពង់ចាមស្រុកសិរីសធ្វរ។

ក៖ ចាពូ។

ខ៖ ស្រុកសិរីសធ្វរ ភូមិព្រែកដំបុក ហើយស្រុកសិរិសធ្វរនិង នៅខេត្តកំពង់ចាម។

ក៖ ចា។ ហើយឥឡូវលោកពូផ្លាស់ទីលំនៅមក នៅភ្នំពេញវិញ?

ខ៖ ចាទឥឡូវគឺមកនៅទីក្រុងភ្នំពេញនិងតែម្តង ចាទរាល់ថ្ងៃនេះ។

ក៖ ចាចុះលោកពូកើតនៅឆ្នាំណា ខែណាដេលលោកពូ?

ខ៖ ខ្ញុំកើតនៅឆ្នាំមួយពាន់ប្រាំបួនរយហុកសិបប្រាំបី នៅថ្ងៃទីប្រាំខែដប់ ត្រូវនិងថ្ងៃអង្គារ
ចាទ។

កៈ ចាចុះលោកពូអើ ថ្ងៃខែឆ្នាំខ្មែរណាស់ ដូចជាឆ្នាំជូត កុល ឆ្លូវអីចឹងណាតើលោកពូឆ្នាំអីគេដែល?

ខៈ ខ្ញុំមានឆ្នាំមមែ។

កៈ ឆ្នាំមមែ។ ចាចឹងអើខ្ញុំចង់សួរលោកពូទៀតថា អើតើលោកពូមានបងប្អូនចំនួនប៉ុន្មាននាក់ដែល?

ខៈ ខ្ញុំមានបងប្អូនប្រាំពីរនាក់។

កៈ ចាចុះលោកពូអាចជួយរៀប់រាប់ឈ្មោះពីកូនទីមួយបន្តិចបានដែលទេលោកពូ?

ខៈ កូនទីបានទាំងអស់ ខ្ញុំជាកូនរៀមច្បងហើយសព្វថ្ងៃនិង។

កៈ ចាហើយលោកពូបន្ទាប់ពីលោកពូហើយ ប្អូនទីពីរនិងមានឈ្មោះអី? ហើយនិងបន្ទាប់ទៀត?

ខៈ ប្អូនទីពីរឈ្មោះ ចាន់ថុល។

កៈ ចាទីពីរឈ្មោះចាន់ថុល។

ខៈ ទីបីរឈ្មោះ គឹមសៀង។

កៈ គឹមសៀង។

ខៈ ទីបួនចាន់ធួន។

កៈ ចាន់ធួន។

ខៈ ទីប្រាំចាន់ធុន

កៈ ចាចាន់ធុន។

ខៈ ទីប្រាំមួយ គឹមសុខា និងគឹមសុខខុម។

កៈ ចឹងទីប្រាំមួយនិងទីប្រាំពីរ គឹមសុខានិង គឹមសុខខុម។

ខៈ ចាទព្រោះពីនាក់បងប្អូនចុងពៅគេនិងភ្លោះ។

ក៖ ចាអរគុណ។
ហើយខ្ញុំចង់សួរទៀតថាតើពួកគាត់ទាំងអស់គ្នាអាឡូវនិងរស់នៅជិតៗគ្នានេះដែល? ឬក៏នៅណាដែល?

ខ៖ គេរស់នៅឆ្ងាយៗ នៅតែជិតតែបីរបួននាក់បងប្អូននិង ចាទក្រៅពីនិងគេសុទ្ធតែនៅឆ្ងាយៗទាំងអស់។

ក៖ ចាគាត់នៅឆ្ងាយនិងគាត់នៅដល់ណាដែលលោកពូ?

ខ៖ នៅឯទៅដល់គ្រាងយៅ
នៅដល់គ្រាងយៅហើយមួយទៀតទៅនៅដល់ឯស្ទែងយៀងអែនុះ។

ក៖ ចាចឹងខ្ញុំចង់សួរលោកពូទៀតថា
លោកពូមានចង់ចាំសាច់រឿងកាលពីលោកពូនៅក្មេងៗណាតើលោកពូធ្លាប់ធ្លាប់ធ្វើអីគេខ្លះជាមួយប្អូនៗ ដូចជារត់លេងឬក៏ធ្វើអីចឹងណាលោកពូ?

ខ៖ អើកាលដែលខ្ញុំនៅកុមារភាពនិងខ្ញុំបាននាំប្អូនៗខ្ញុំនិងទៅសាលារៀនដែល។
នាំទៅរៀនសូត្រនៅឯសាលាភូមិអូរអំបិល ស្រុកសិរីសោភ័ណ្ឌឯនុះ
ព្រោះកាលនិងខ្ញុំទៅរស់នៅឯនិង ដល់តែក្រោយមកទៀតបានជាខ្ញុំអើត្រលប់មកវិញ
គឺខ្ញុំមករស់នៅទីក្រុងភ្នំពេញវិញ។

ក៖ ចាលោកពូ។

ខ៖ និងខ្ញុំរៀនសូត្រមិនសូវបានច្រើទេ បានត្រឹមថ្នាក់ទីពីរ ទីបីរយើងអាឡូវនេះទេ
ព្រោះកាលនិងគ្រាប់បែកវាផ្លោងពេក កាលពីឆ្នាំប៉ែតសិបអីនិង
ខ្ញុំរៀនមិនបានព្រោះគ្រាប់ផ្លោងពេក បានជាខ្ញុំនាំម៉ែឪបងប្អូនរត់មកនៅទីក្រុងភ្នំពេញវិញ។
ដល់តែពេលចុះមកដល់ភ្នំពេញនេះហើយចេះតែខំរកស៊ីទៅ ខ្ញុំខំរកស៊ីដើម្បីជួយគ្រួសារ
ជួយចិញ្ចឹមឪពុកម្តាយនិងបងប្អូនដែលនៅតូចឯនុះ។

ក៖ ចាលោកពូ។

ខ៖ ហើយសព្វថ្ងៃនិង ឥឡូវនេះខ្ញុំវាមានវ័យជំនាស់ចាស់ហើយ គឺហារសិបបីរឆ្នាំហើយ
ខ្ញុំធ្វើអីលែងកើតហើយ
បានតែកូនៗនិងចេះទៅរកស៊ីមកបានផ្តល់អោយខ្ញុំតិចតួចជាជំនីអាហារអីអោយខ្ញុំហូបចុក

ណាមួយទៅខ្ញុំមិនសូវជាផង ងាកឈឺៗ ហើយសព្វថ្ងៃនេះកូនៗគេចេះទៅរកស៊ី
គេធ្វើការងាគេខាងកាត់ដេរ អាខ្លះទៀតធ្វើការនៅខាងអង្គារឯនុះ
បានកូនចៅធំៗទៅវាបានចេះជួយថែទាំឪពុកម្ដាយ។
ខ្ញុំគ្មានអីទេមានតែពាក្យប៉ុននិងផ្ដាំផ្ញើរ។

ក៖ ហាហាហាចា។ ចឹងខ្ញុំសូមអរគុណលោកពូ
ចឹងអើខ្ញុំចង់សួរលោកពូទៀតថាឪពុកម្ដាយលោកពូមានឈ្មោះអីគេខ្លះដែល។

ខ៖ ឪពុកខ្ញុំមានឈ្មោះថា កួច ចឹង។ ម្ដាយខ្ញុំមានឈ្មោះថាទឹង ថាច។

ក៖ ចាអើចុះពួកគាត់កើតនៅឆ្នាំណា ខែណាដែលលោកពូមានដឹងទេ?

ខ៖ ខ្ញុំអត់បានចាំទេតែខ្ញុំដឹងថាគាត់ព្រះជន្មសព្វថ្ងៃនេះ ជាងប៉ែតទៅហើយ។

ក៖ ចាហើយឪពុកម្ដាយនៅរស់សព្វថ្ងៃលោកពូ?

ខ៖ ខ្ញុំមាននៅរស់តែឪពុកទេ ម្ដាយខ្ញុំខូចយូណាស់មកហើយគឺជាងមួយម្ភៃឆ្នាំមកហើយ។

ក៖ ចាចឹងគាត់ខូចនិងជាងមួយម្ភៃឆ្នាំហើយតាំងពីលោកពូអាយុប៉ុន្មានដែល?

ខ៖ កាលដែលគាត់ខូចនិង គឺខ្ញុំមានអាយុសាមជាងដែក។

ក៖ ចាចឹងសាមជាងរហូតមកដល់ឥឡូវនិងលោកពូហារជាង
ចឹងវាដូចជាមួយម្ភៃឆ្នាំជាងហើយនុះលោកពូ?

ខ៖ បាទគឺគាត់បានខូចនិងជាងមួយម្ភៃឆ្នាំហើយម្ដាយខ្ញុំនុះ។

ក៖ ចាចុះលោកពូមានចាំថ្ងៃខែឆ្នាំកំណើតគាត់ដូចជាឆ្នាំខ្មែរ
តើពួកគាត់កើតនៅឆ្នាំអីគេដែលដូចជាឆ្នាំជូត ឆ្នាំឆ្លូវអីណា?

ខ៖ ខ្ញុំអត់ដែលស្គាល់ ប៉ុន្នែខ្ញុំគ្រាន់តែដឹងថាឪពុកខ្ញុំមានឆ្នាំថោះ ម្ដាយខ្ញុំឆ្នាំខាល។

ក៖ ចា ហើយចុះស្រុកកំណើតពួកគាត់នៅណាដែលលោកពូ?

ខ៖ អើឪពុកខ្ញុំនៅឯកំពង់ចាមឯនុះ ឯម្ដាយខ្ញុំវិញនៅឯគ្រាងយៅ
បាទគាត់នៅគ្រាងយៅគាត់ស្លាប់នៅគ្រាងយៅនិងដែល។

កៈ ចាលោកពូ ហើយចុះលោកពូឪពុករបស់លោកពូណាតើគាត់ប្រកបមុខរបបអីខ្លះសំរាប់ចិញ្ចឹមកូនចៅអីចឹងណាលោកពូ?

ខៈ កាលពីអាដែងខ្ញុំដឹងក្ដីមក គឺគាត់ធ្វើឥតការ៉ូ គឺឥតការ៉ូខ្មែរយើងនិង គាត់ធ្វើយកលុយមកចិញ្ចឹមកូនទល់តែសព្វថ្ងៃនិង ឥឡូវគាត់មានអាយុប៉ែតសិបប្រាំពីរ ប៉ែតសិបប្រាំបីហើយ ហើយគាត់ចាស់ជរាហើយគាត់គ្មានធ្វើអីទៀតទេ គឺគាត់នៅតែផ្ទះ។

កៈ ចុះពេលគាត់ធ្វើឥតធ្វើអីនិង តើលោកពូមានជួយធ្វើគាត់ទេកាលនិង? ហាហាហា។

ខៈ កាលនិងខ្ញុំបានជួយធ្វើគាត់ ហើយគាត់បានបង្រៀនខ្ញុំអោយចេះធ្វើឥតនិងរហូត ទល់តែខ្ញុំបានឡើងធ្វើដល់តែមេជាង។
ហើយខ្ញុំចេះមួយចប់ព្រោះគាត់បង្រៀនតាំងពីធ្វើពុំព ប្រដាប់ចាក់ផ្កាផ្ញើតាបរបង់វត្តអីៗនិង គឺគាត់បានវង្រៀនខ្ញុំអោយចេះបានមួយចប់របស់គាត់
បាទហើយខ្ញុំក៏បានចេះស្ទាត់ពីគាត់និង
តែសព្វថ្ងៃនេះឥតការ៉ូនិងអត់ដែលឃើញមានគេធ្វើទេ ហាហាហា
បាទកាលនិងខ្ញុំធ្វើនៅឆ្នាំប៉ែតជាងនិងគឺខ្ញុំធ្វើតែជាមួយគាត់និង។

កៈ ចាលោកពូ។

ខៈ បើខ្ញុំមិនបានទៅធ្វើមានប្អូនស្រីខ្ញុំមួយនិងទៅជួយធ្វើគាត់ទៅ ជួយចាក់ពណ៌ផ្ការអីផ្ការគឺគាត់មិនដែលបានធ្វើឥតអីនិងគេទេ
តែគាត់ជួយចាក់តែផ្ការតាមរបង់វត្តនិងព្រោះវត្តកាលនិងគេត្រូវការក្រាលណាស់
ហើយគាត់និងចេះតែធ្វើទៅមួយថ្ងៃបានជាងមួយរយសន្លឹកដែល។

កៈ ចាលោកពូ។

ខៈ
ហើយដល់តែពេលខ្ញុំបានរៀនេពីគាត់ចេះសព្វគ្រប់ហើយនិងខ្ញុំក៏ចេញទៅធ្វើខ្លួនឯងមួយដង។ ខ្ញុំចេះធ្វើបានដូចជាគាត់ដែល។

កៈ
ចាចឹងខ្ញុំចង់សួរលោកពូទៀតថាចុះម្ដាយរបស់លោកពូវីញតើគាត់បានធ្វើអីគេខ្លះសំរាប់ចិញ្ចឹមជីវិតរបស់គាត់ណាស់លោកពូ?

ខ៖ ចាទគឺគាត់បានលក់ដូរនៅឯផ្សារឯនុះ គាត់លក់ដូរចឹងមក ឯឪពុកខ្ញុំអីនុះទៅវែតតការ៉ូចឹងទៅផ្សំគ្នាចិញ្ចឹមកូនបានទាំងប្រាំពីរនាក់និង ហាហាហារ រហូតទល់តែកូនមានប្ដីមានប្រពន្ធរៀងៗខ្លួនចឹងទៅបានពួកយើងបែកពីគាត់មក។ ហើយដល់ពេលយើងរកបានចឹងចេះតែនាំគ្នាជូនគាត់ទៅ ព្រោះអីពួកគាត់និងចាស់ៗអស់ហើយ បាទ។

ក៖ ចាហើយចុះខ្ញុំចង់សួរលោកពូទៀតថា ពួកគាត់ណាធ្លាប់ប្រាប់លោកពូអំពីជីវប្រវិត្តរបស់ពួកគាត់កាលេពីគាត់នៅក្មេង ថាគាត់ធ្វើអីដែលទេលោកពូ?

ខ៖ គាត់ធ្លាប់និយាយប្រាប់ខ្ញុំថា ម្ដាយខ្ញុំកាលនិង កាលពីដើមឡើយមកគាត់នៅ ថានៅតែនិងផ្ទះទេហើយអើ ហើយឪពុកខ្ញុំនិងគាត់ធ្វើជាទាហាន គាត់ធ្វើទាហានយើងនិងហើយដល់តែក្រោយមកអាដែងនេះគាត់បានទៅធ្វើជាគ្រូបង្រៀន ។

ក៖ ចាលោកពូ។

ខ៖ គាត់ជាគ្រូបង្រៀនសិស្សយើងនិង ហើយប៉ុន្តែគ្រាន់តែខ្ញុំដឹងថាគាត់និងជាអ្នកធ្វើការនៅឯចំការកៅស៊ូយើងនិងនៅឯជិតសៀង មេមុតអីនិងគាត់ធ្លាប់កាន់ខាងនេះ បើនិយាយាទៅគាត់អ្នកធ្វើការគ្រាន់បើដែលកាលនិង គាត់បានរៀនចប់ឌីផ្លូមដែល ឪពុកខ្ញុំនិងគាត់មានសញ្ញាបិតច្រើនណាស់ប្រាំ ប្រាំមួយឯនុះ។

ក៖ ចាលោកពូ។

ខ៖ ហើយមកដល់សព្វថ្ងៃនេះគាត់ចាស់គាត់ធ្វើអីទេ ព្រោះគាត់ប៉ែតជាងហើយ។

ក៖ ចាស់គាត់អាយុច្រើន ត្រូវហើយលោកពូ។ ចាចឹងខ្ញុំចង់សួរលោកពូទៀតថាតើជីដូនជីតារបស់លោកពូខាងឪពុកណា ពួកគាត់មានឈ្មោះអីគេខ្លះដែល?

ខ៖ ពួកគាត់មានឈ្មោះអើ កុងទេង និងមាលី។

ក៖ ចាចុះពួកគាត់អើកើតនៅឆ្នាំណាដែលលោកពូចាំទេ?

ខ៖ អត់ទេខ្ញុំមិនបានចាំទេព្រោះគាត់
នែកអាដែងនេះនិងខ្ញុំកើតមកអត់ទាន់អាដែងនែកម៉ាខ្ញុំគាត់ខូចផងនិង។

ក៖ ចាចឹងពួកគាត់ស្លាប់អស់ហើយ?

ខ៖ បាទពួកគាត់ខូចអស់ហើយ អត់មាននៅសល់ទេ។

ក៖ ចាហើយចុះជីដូនជីតាខាងអើម្ដាយវិញ តើលោកពូមានដឹងថាគាត់ឈ្មោះអីទេ?

ខ៖ អើតាខាងម្ដាយឈ្មោះថា តាទឹង ហើយយាយឈ្មោះយាយ ប៊ុន។

ក៖ ចាហើយពួកគាត់ស្លាប់អស់ហើយដែល?

ខ៖ បាទពួកគាត់ស្លាប់អស់ហើយ។

ក៖ ចាចុះលោកពូមានចាំថាពួកគាត់ស្លាប់នៅកន្លែងណា
ហើយមានស្រុកកំណើតអីគេដែលលោកពូ?

ខ៖ ពួកគាត់ស្លាប់នៅគ្រាងយ៉ៅទាំងអស់
ស្រុកកំណើតម្ដាយខ្ញុំគាត់ស្លាប់នៅគ្រាងយ៉ៅនិងទាំងអស់។

ក៖ ចាលោកពូ។

ខ៖ ហើយខាងឪពុកខ្ញុំគាត់ស្លាប់នៅកំពង់ចាមទាំងអស់។

ក៖ ចា។

ខ៖ បាទគឺពួកគាត់បានស្លាប់នៅស្រុកកំណើតគាត់ទាំងអស់គ្នានិង
គាត់អត់មានផ្លាស់ទីលំនៅទៅណាទេ
ម្ដាយខ្ញុំពេលគាត់ស្លាប់ក៏ទៅស្លាប់នៅឯស្រុកកំណើតរបស់គាត់វិញដែល
គឺដូចតេគ្នាទាំងអស់និង។

ក៖ ចាចុះបងប្អូនរបស់លោកពូដែលពួកគាត់មានក្រុមគ្រួសារហើយណាអើ
តើពួកគាត់រស់នៅខេត្តផ្សេងៗគ្នាហើយនិងរស់នៅទីនេះប្រហែលប៉ុន្មាននាក់ដែលលោក
ពូ?

ខ៖ នៅទីនេះសព្វថ្ងៃនៅតែប្រាំនាក់ទេ។

ក៖ នៅទៅនេះតែប្រាំនាក់ទេ?

ខ៖ បាទ។

ក៖ ហើយក្រៅពីនិងនៅឯណាវិញដែលលោកពូ?

ខ៖ គេនៅឆ្ងាយៗ ណាស់បាទគេនៅឆ្ងាយ។

ក៖ ចា។

ខ៖ និងហើយពួគាត់សុទ្ធតែនៅឆ្ងាយៗ។

ក៖ ហើយចុះពួកគាត់រស់នៅដល់ស្រុកណាខ្លះដែលលោកពូ?

ខ៖ ចង់សួរពីពីណាគេ?

ក៖ អើបងប្អូនលោកពូណា។

ខ៖ អរពួកគេនៅខាងឯកាទូតសៀមរាបឯនុះ។

ក៖ អរចា។

ខ៖ ហើយមួយទៀតនៅក្រាងយ៉ៅ នៅឯស្រុកកំណើតម្តាយខ្ញុំឯនុះ។

ក៖ ចាលោកពូ។ ហើញអើ ខ្ញុំចង់សួរលោកពូថា
តើលោកពូមានសាច់ញ្ញាតិបងប្អូនដែលរស់នៅប្រទេសក្រៅដែលឬទេលោកពូ?

ខ៖ ខ្ញុំអត់មានទេ។

ក៖ ចា ហើយចឹងពួកគាត់រស់នៅស្រុកខ្មែរទាំងអស់គ្នា។ ចឹងតើលោកពូមានប្រពន្ធ
គាត់មានឈ្មោះអីគេដែលលោកពូ?

ខ៖ សព្វថ្ងៃនិងអី?

ក៖ ចា។

ខ៖ បាទប្រពន្ធខ្ញុំឈ្មោះទុន។

ក៖ ឈ្មោះទុន គាត់មានត្រកូលអីដែលលោកពូ?

ខ៖ បាទគឺឈ្មោះពេញ ជុំ ទុន។

ក៖ ចាហើយលោកពូមានកូនប៉ុន្មាននាក់ដែល?

ខ៖ ខ្ញុំសព្វថ្ងៃកូនមិនតិចទេ គឺដប់ពីរនាក់ឯនុះ។

ក៖ វោមានកូនច្រើនណាស់លោកពូ។

ខ៖ បាទ ហាហាហា។ កូនដល់ទៅដប់ពីនាក់ឯនុះ  កូនប្រុសប្រាំមួយ ស្រីប្រាំមួយនាក់។

ក៖ ចាហើយពួកគាត់រៀបការអស់ហើយលោកពូ?

ខ៖ នៅគឺនៅតែប្រាំទេ ក្រៅពីនិងគេមានប្ដី មានប្រពន្ធអស់ហើយ គេមានគ្រួសារអស់ហើយ នៅតែតូចៗទេ។

ក៖ ចាហើយពួកគាត់រៀបការអស់ហើយពួកគាត់រស់នៅឯណាដែលលោកពូ?

ខ៖ ពួកគេរស់នៅឆ្ងាយៗណាស់។

ក៖ រស់នៅឆ្ងាយៗ។

ខ៖ បាទ។ គេអត់នៅនេះទេ គេទៅតាមប្ដីគេ គេទៅតាមប្រពន្ធគេអីចឹងទៅ។ គេនាំគ្នាទៅនៅឆ្ងាយៗណាស់ទល់តែមានបុណ្យទានអីចឹងទៅបានពួកគាត់មកជួបជុំគ្នាអីចឹងទៅ បើមិនចឹងទេពួកគាត់នៅជាប់ការងារគ្នារកស៊ី វាមិននេះទេកូនខ្ញុំនិងព្រោះពេលខ្លះវាពីបាកផងដោយសារតែផ្លូវវាឆ្ងាយណាស់ វាពិបាកចឹងបានមកលេងតែបុណ្យទានអីនិងម្ដងៗណា។

ក៖ ចាចឹងខ្ញុំចង់សួរលោកពូទៀតថាតើលោកពូបានរៀបអាពាហ៍ពីពាហ៍នៅឆ្នាំណាដែលលោកពូ?

ខ៖ អើកាលដែលខ្ញុំរៀបនិងនៅឆ្នាំទី ប៉ែតសិបប្រាំពីរ។

កៈ ចាហើយចុះថ្ងៃ?

ខៈ នេះអើខ្ញុំដូចជាមិនបានចាំថ្ងៃទេ គ្រាន់តែដឹងថាខ្ញុំការនៅឆ្នាំទីប៉ែតសិបប្រាំពីរ។

កៈ ចានៅឆ្នាំទីប៉ែតសិបប្រាំពីរ។ ហើយចុះនៅកន្លែណា ភូមិណាដែលលោកពូ?

ខៈ កាលដែលខ្ញុំការនិងខ្ញុំនៅក្រាំងយ៉ៅ។

កៈ ការលោកពូនៅក្រាំងយ៉ៅ នៅភូមិសង្កាត់អីគេដែលលោកពូ?

ខៈ បាទនៅភូមិអើ នៅភូមិពីងពុង ឃុំក្រាំងយ៉ៅ ស្រុកស្អាង ខេត្តកណ្តាលយើងនេះឯង។

កៈ ចាហើយចុះអើ
ការរៀបអាពាហ៍ពិពាហ៍និងតើត្រូវបានដឹងលឺដល់ឪពុកម្តាយេជាអ្នករៀបចំអោយ
ឬក៏លោកពូរៀបដោយចិត្តខ្លួនឯងដែលលោកពូ?

ខៈ ការរៀបអាពាហ៍ពិពាហ៍និង គឺឪពុកម្តាយខ្ញុំជាអ្នកចូលស្តីដណ្តឹងគេការមកត្រឹមត្រូវ
តាមក្បួនប្រពៃណីខ្មែរយើង។

កៈ ចា។

ខៈ អត់មានអោយខ្វះខាតអីត្រង់ណាទេ។ ហាហាហា។

កៈ ចាហើយខ្ញុំចង់សួរលោកពូទៀតថាតើលោកពូអោយថ្លៃជំនូនគេប៉ុន្មានដែល?

ខៈ កាលដែលនេះនិង កាលនិងគេទាយកអើ កាលនិងនៅចាយលុយកាក់និង
គេយកតែប៉ុន្មានពាន់តាស់ ប្រាំពីរ ប្រាំបីពាន់លុយយើងឥឡូវទេ។

កៈ ចា។

ខៈ ប៉ុនន្តែលុយកាលនិងនៅថ្លៃណាស់
ហើយកាលនិងលុយយើងនៅចាយមួយកាក់ៗនៅឡើយនិង។

កៈ ចាត្រូវហើយលោកពូ។

ខៈ ហើយបើថាគិតទៅ ខ្ញុំបានអោយគេមួយម៉ឺនប្រាំ អោយគេទៅទិញខោអាវអីៗនិង
ទល់តែពេលការនៅលើយើងទៀតទៅ ហាហាហា បាទវាអត់មានអីប៉ុន្មានទេនៅកាលនិង

គ្រាន់តែបានអើការពីរយប់ពីរថ្ងៃដូចតែគេដូចឯងដែលនិង។
មិនមែនទៅរត់តាមគ្នាទេប្រពន្ធការពេញច្បាប់ ហាហាហា។

កៈ ចាត្រឹមត្រូវអំ។ ហើយចឹងខ្ញុំចង់សួលោកពូទៀតថាអើ
តើលោកពូជួបជាមួយអ្នកមីងដំបូងណានៅពេលណាដែល?
ហើយមេចបានជាស្រលាញ់គ្នា? បានចាប់ដៃគ្នាជាប្ដីប្រពន្ធមកចឹង?

ខៈ កាលនិងខ្ញុំមិនបានទៅស្រលាញ់អីទេ
ប៉ុនន្តែនែកអើពេលខ្ញុំមកពីធ្វើទ័ព្វនោះវិញម្ដាយខ្ញុំគាត់រៀបចំអោយ។

កៈ ម្ដាយគាត់រៀបចំអោយ។

ខៈ បាទកាលនិងខ្ញុំនៅឯខេត្តបាត់ដំបងឯនុះ កាលនិងខ្ញុំនៅធ្វើទ័ព្វនៅខេត្តបាត់ដំបងនៅឯ
ខ្ញុំទៅឈរជើងនៅឯមួយដុំបាក់ប្រេង នៅកន្លែងព្រៃកទ័ព្វយើងនៅឯសាលាតាអនឯនុះ
នៅក្នុងកន្លែងទន្លេសាបគេ ដល់តែពេលខ្ញុំសូមច្បាប់គេមកលេងផ្ទះ
ពេលមកលេងគាត់ក៏រៀបចំការអោយទៅ។

កៈ ចាលោកពូ។

ខៈ ខ្ញុំមកទើបតែបានប្រហែលជាកន្លះខែ ហើយខ្ញុំសូមច្បាប់គេបានបីរខែកាលនិង
ដល់តែពេលខ្ញុំការហើយចឹងទៅគាត់លែងអោយខ្ញុំទៅវិញទល់តែរាល់ថ្ងៃនិង
ហើយកាលដែលខ្ញុំនៅធ្វើការនិងក៏សាក់ពីរអីដែលកាលនិង
គឺសាក់ពីរកាលជំនាន់ប្រយុទ្ធនិង
ហើយដល់តែហើយទៅបានអើបងប្អូនខ្ញុំនិងណាថាបងឯងមិនបាច់ទៅវិញទេ
ហើយខ្ញុំបានទៅមួយសសារដែល
ដល់តែរួចទៅគាត់ថាអើបើមានប្រពន្ធកូនហើយមិនបាច់មកវិញក៏បានដែល
ប្រាធាននុរក្សខ្ញុំនិង ប៉ុន្តែគេថាស្រេចតែចិត្តទេចង់មកនៅក៏មក
បើមិនចឹងទេទៅផ្ទះវិញក៏ទៅៗ ប៉ុនន្តែគាត់ធ្វើច្បាប់អោយមក
ពេលគាត់ធ្វើច្បាប់អោយមកបានអាដែងនេះ
ហើយបានកាលនិងគេចាប់ទាហានខ្លាំងណាស់
ហើយខ្ញុំមានច្បាប់ទំលាប់អីរបស់ខ្ញុំត្រឹមត្រូវចឹងទៅក៏គេគ្មានរណាមកហានចាប់អីខ្ញុំទេ
ព្រោះខ្ញុំមានសំបុត្រស្នាំមអីរបស់ខ្ញុំត្រឹមត្រូវ។ បាទហើយក៏ខ្ញុំលែងនេះទៅ

ក៏ខ្ញុំចេះតែដើររកស៊ី មករកស៊ីជាមួយឪពុកខ្ញុំនិងរហូតមកដល់ឥឡូវនិង គឺមកធ្វើឥតការវ៉ូវិញ។ ខ្ញុំមកធ្វើឥតការវ៉ូយើងនិងបានមួយអាទិត្យអីចឹងទៅ បានដប់ថ្ងៃអីចឹងទៅ ខ្ញុំក៏ទៅផ្ទះវិញព្រោះកាលនិងខ្ញុំគ្នាអីជិះទេ គឺជិះតែកង់មកនិង ហាហាហា។

ក៖ ចាលោកពូ។

ខ៖ រាល់ថ្ងៃនិង អាឡូវនិងវាមិនដូចពីមុនវាមិនដូចឥឡូវទេ ឥឡូវនិងសម័យគេទំនើបណាស់។

ក៖ ចាមានម៉ូតូ មានឡាន មានអី ហាហាហា។

ខ៖ បាទឥឡូវនិងមានអីទេ គឺកូនអត់អោយខ្ញុំធ្វើអីទេ ព្រោះឪពុកចាស់ហើយ ឪពុកកុំធ្វើអីនៅតែផ្ទះទៅហាហាហា។

ក៖ ចាល្អមែនទែន ហាហាហា។

ខ៖ បាទព្រោះកូនធំៗអស់ហើយកូនមានប្តីមានប្រពន្ធអស់ហើយ ហើយគេថាឪពុកបើខ្វះខាតអីតេទៅប្រាប់គេទៅ គេនិងផ្តល់មកអោយហើយ។

ក៖ ចាកូនលោកពូពួកគាត់កន្លងធម៏ល្អ។

ខ៖ បាទពេលខ្វះខាតអីអោយតេទៅ ពេលឈឺយប់ថ្ងៃអី គេប្រាប់ថាកូនណានៅជិតអោយយកទៅពេទ្យកុំអោយខាន អស់លុយប៉ុនន្មានអី ប៉ុនន្មានចាំគេជាអ្នកផល់មកអោយ។ អានិងកូនៗរបស់ខ្ញុំសព្វថ្ងៃនិង។

ក៖ ចា។

ខ៖ ហើយកូនខ្ញុំនិងវាបានដោយសុទ្ធតែកន្លងធម៏ទាំងអស់ អត់មានកូនណាមួយខូចខិល ជក់ម៉ា ជក់ថ្នាំញៀនអីទេ កូនខ្ញុំដោយកន្លងធម៏ទាំងអស់ អានិងកូនខ្ញុំសព្វថ្ងៃនិង។ កូនប្រុសក៏ដូចកូនស្រី កូនស្រីក៏ដូចកូនប្រុសទាំងអស់ ចេះគោរពឪពុកម្តាយណាស់។

ក៖ ចាចឹងអរគុណច្រើនលោកពូ ហើយខ្ញុំចង់សួរលោកពូទៀតថា តើលោកពូបានរៀនដល់ថ្នាក់ទីប៉ុន្មានដែល?

ខ៖ បាទខ្ញុំរៀនបានថ្នាក់ទីពីរថ្មីយើងឥឡូវនិង។

ក៖ អរចា។

ខ៖ ខ្ញុំរៀនបានទាបណាស់ ហើយកាលនិងខ្ញុំចេះតែដើររកស៊ីជួយចិញ្ចឹមប្អូនៗ
កាលនិងប្អូនៗខ្ញុំនៅតូចៗណាស់ ហើយខ្ញុំទៅរៀនក៏វាមិនបានចិតថ្លៃដែល
ព្រោះកាលនិងពេលខ្ញុំរៀន គេបាញ់គ្រាប់ផ្លោង ដូចខ្ញុំបាននិយាយប្រាប់ថា
កុំពង់តែរៀននិងជូនកាល។

ក៖ ការនិងនៅជំនាន់អីគេដែលលោកពូ?

ខ៖ បាទនៅជំនន់យើងឥឡូវនិង។

ក៖ អើខ្ញុំចង់និយាយថានៅជំនាន់គ្រាប់ផ្លោងនិងណា?

ខ៖ អរនៅឆ្នាំទី ប៉ែតសិបមួយ ប៉ែតសិបពីរយើងនិង។

ក៖ ចាតែនៅគេបាញ់គេអីចឹងទៅ?

ខ៖ បាទគ្រាប់ផ្លោងហើយបាញ់គ្នា នាំគ្នាគេចវង់វេញវង់វន្តអស់ហើយ។

ក៖ ចា។

ខ៖ ដល់តែខ្ញុំមើលទៅពីបាកពេក មើលទៅរៀនក៏មិនកើតធ្វើអីក៏មិនកើត
ខឹងណាស់ក៏ខ្ញុំនិងរត់មកធ្វើទារហាន ខ្ញុំបានស្ម័គ្រចិត្តធ្វើជាទារហាននៅឆ្នាំទីប៉ែតសិបបួន។
និងខ្ញុំបានចូលធ្វើជាទារហាននៅឆ្នាំទីប៉ែតសិបបួននិង
ដល់តែពេលឆ្នាំទីប៉ែតសិបប្រាំពីរបានខ្ញុំឈប់សំរាកនិង
ព្រោះកាលនិងក៏គេនៅកំពង់បាញ់គ្នាដែល ហាហាហា ហើយក៏គេចាប់ដែល
តែខ្ញុំកាលនិងវានៅវ័យក្មេងដែលនិង
ប៉ុន្តែឥឡូវនេះវាចាស់ជាងហារហើយវាមានអីទៀត។

ក៖ ចាហើយចុះអើសាលាដែលលោកពូធ្លាប់រៀនពីក្មេងណាស់ នៅសាលាណា?
ហើយមានឈ្មោះអីគេដែលលោកពូ?

ខ៖ កាលនិងអី កាលដែលខ្ញុំនៅរៀននិង ខ្ញុំនៅឯស្វាយស៊ីសុផនឯនុះ។

ក៖ ចាថៃមែនលោកពូ?

ខ៖ បាទគេហៅថាសាលា អូអំបិល។

ក៖ ថៃអីក៏ខ្មែរ?

ខ៖ ខ្មែរយើងតាស់។

ក៖ នៅខ្មែរយើង ខ្មែរស៊ីសុផន។

ខ៖ បាទនៅសាលាអូអំបិលយើង ស្រុកសិរីសោភ័ណ្ឌ អើគេហៅខេត្ត
កាលពីមុនមិនទាន់ដាក់ខេត្តបន្ទាយមានជ័យទេ
ពីមុននិងនៅជាខេត្តបាត់ដំបងនៅឡើយទេ កាលដែលខ្ញុំនៅរៀន
ដល់អាឡូវនេះគេបង្កើតខេត្តបន្ទាយមានជ័យ ហាហាហា។

ក៖ ចាហាហាហា។ ហើយចឹងខ្ញុំចង់សួរលោកពូទៀតថា
តើលោកពូមានមិត្តភក្តិដែលធំឡើងស្និតស្នាលជាមួយគ្នាដែលឬទេលោកពូ?

ខ៖ ទេរាល់ថ្ងៃនិងវាភ្លេចគ្នាអស់ហើយ មិត្តភក្តិស្និទស្នាល ពីកាលដែលនៅវ័យសិក្សានិង
អាឡូវនិងវាភ្លេចគ្នាអស់ហើយទោះបីជាឃើញគ្នា មិនស្រួលនិងក៏អត់ស្គាល់គ្នាដែល
ព្រោះចាស់ៗអស់ហើយ ឡើងហារជាងទៅហើយ។
ហើយមួយជំនាន់នើខ្ញុំនិងណាមួយវាបាញ់គ្នាផងអីផង
ហើយមិនដឹងថាពីណាទៅនៅត្រង់ណា ពីរណាទៅនៅត្រង់ណាអស់ហើយទេ។

ក៖ ចាលោកពូ។

ខ៖ វាអត់ដឹងដែលសព្វថ្ងៃនិង មានតែប៉ុននិង។

ក៖ ចាអើចឹងខ្ញុំចង់សួរលោកពូទៀតថា
តើលោកពូធ្លាប់ធ្វើការនៅវាល់ស្រែដែលឬទេលោកពូ? ធ្លាប់ធ្វើស្រែ ធ្វើអីចឹងណា?

ខ៖ ខ្ញុំអត់ដែលធ្វើទេស្រែ។

ក៖ ចា។

ខ៖ ខ្ញុំនិយាយប្រាប់ត្រង់ខ្ញុំអត់ចេះតែម្តង។

ក៖ ចាអត់អីទេលោកពូ ចា។

ខ៖ បានតែធ្វើការងារអីអានិងចេះដល់តែធ្វើស្រែអី ខ្ញុំមិនដឹងគេធ្វើយ៉ាងមេចទេអានិង បើអត់ដែលធ្វើផង។

ក៖ ចាចុះលោកពូធ្លាប់ធ្វើអាជីវកម្មអីផ្សេងៗសំរាប់ចិញ្ចឹមក្រុមគ្រួសារដែលឬទេលោកពូ?

ខ៖ ខ្ញុំអត់ដែលផងតែស៊ីឈ្នួលគេ ឬមួយខ្ញុំម៉ៅគេអីចឹងទៅ ខ្ញុំធ្វើការវាមានតែចឹងទេ។

ក៖ ចាហើយលោកពូធ្វើការខាងអីគេដែលលោកពូ?

ខ៖ កាលនិងខ្ញុំធ្វើជាងដែកផង ហើយនិងជាងសំណង់ផង។

ក៖ ចាជាងដែកផង ជាងសំណង់ផង។

ខ៖ បាទ។

ក៖ ចាចុះតាំងតែពីក្មេងរហូតមកដល់អាឡូវនិង ចង់សួរថាតើលោកពូមើលឃើញថា ជីវិតរបស់លោកពូមានការផ្លាស់ប្តូរអីគេខ្លះដែលលោកពូ?

ខ៖ តាំងពីក្មេងរហូតមកដល់ឥឡូវនេះ ខ្ញុំមានមានជីវិតផ្លាស់ប្តូរច្រើនណាស់ កាលពីមុនខ្ញុំធ្លាប់ ភ្នែកខ្ញុំវានៅភ្លឺច្បាស់មើលវាធ្វើការអីរហ័សរហួន ដល់តែពេលចាស់ទៅខ្ញុំវាស្រវាំងភ្នែក ដល់តែពេលស្រវាំងភ្នែក វាធ្វើអីក៏លែងលកើត ស្វប្បីតែអាដែងនេះនិង ខ្ញុំខូចភ្នែកខូចពេលដែលធ្វើជាងដែកនិងឯង ធ្វើជាងដែកនិងវាដល់តែពេលចាស់ទៅ វាទៅជាងងឹតភ្នែកនិងណាបានខ្ញុំថា អើយកូនចៅទាំងអស់កុំធ្វើជាជាងដែកទៀត ព្រោះអីអាដែងនេះនិងខ្លាចវាងងឹតភ្នែកដូចជាខ្ញុំ។ ឥឡូវបានអាប្អូនខ្ញុំមួយនិងវាចេះ វារៀនទៅចេះវាទៅបើកសិបក្បកម្មនិងខ្លួនឯងទៅ។

ក៖ ចាលោកពូ។

ខ៖ បានប្អូនប្រុសមួយ អាមួយដែលនៅឯស្ពឺនិង។

ក៖ ចាចុះលោកពូជាងដែកនិងធ្វើខ្លួនឯង ឬក៏ធ្វើការអោយគេ?

ខ៖ ខ្ញុំម៉ៅ ម៉ៅអោយគេ។

ក៖ ម៉ៅអោយគេចា។

ក៖ ចាហើយចឹងខ្ញុំចង់សួរលោកពូទៀតថា
តើមានម្ហូបណាដែលលោកពូចូលចិត្តខ្លាំងជាងគេនៅក្នុងជីវិតរបស់លោកពូណា?

ខ៖ បាទខ្ញុំចូលចិត្តតែសំល្លរម្ជូរ។

ក៖ អរលោកពូចូលចិត្តសំល្លរម្ជូរ ឆ្ងាញ់ហាហាហា។

ខ៖ បាទ។

ក៖ ហើយអើខ្ញុំចង់សួរលោកពូទៀតថា តាំងពីក្មេងមកណា
តើលោកពូធ្លាប់លេងល្បែងកំសាន្តអីខ្លះដែលលោកពូចូលចិត្តលេង? លេងដូចបោះអង្គុញ
ចើលឈូកអីណា តើលោកពូមានទេ?

ខ៖ បាទខ្ញុំចូលចិត្តលេងបាល់ទាត់។

ក៖ អរលេងបាល់ទាត់។

ខ៖ បាទ មួយជីវិតខ្ញុំនិងចូលចិត្តណាស់រឿងបាល់ទាត់ ព្រោះខ្ញុំពីក្មេងខ្ញុំធ្លាប់លេងបាល់
ហើយខ្ញុំអត់ដែលមានចង់លេងអីក្រៅពីបាល់ទេ។

ក៖ ចាចឹងលោកពូគឺជាមនុស្សម្នាក់ដែលស្នេហាវិស័យកីឡារ?

ខ៖ បាទខ្ញុំចូលចិត្តណាស់រឿងខាងបាល់និង អោយតែបាល់ទះ បាល់បោះអីនិងក៏ចង់មើល
ចង់ឃើញកាលគេលេងបាល់ទាត់និងអរ អោយតែគេលេងនិងខ្ញុំទៅហើយ
ខ្ញុំមិនដែលខានទេចូលចិត្តណាស់ព្រោះកាលនិងខ្ញុំនៅក្មេងខ្ញុំលេងតែបាល់ទាត់និង
ហាហាហា។

ក៖ ចាល្អ។

ខ៖ ខ្ញុំលេងបាល់កាលនៅសិស្សនិងខ្ញុំធ្លាប់លេងបាល់
ដែលខ្ញុំនៅរៀននិងលេងជាមួយកូនសិស្សគ្នាឯងនិងនាំគ្នាទាត់បានពានរំវាន់ដែលកាលនិង
។

ក៖ វោទាត់បានពានរំវាន់ទៀត។

ខ៖ បាទបាន តែកាលនិងគ្មានពានរំវាន់អីទេ បានតែនែក។

ក៖ ការសរសើរ?

ខ៖ គឺអាកាក់មូលៗគេនិង អានិងគេហៅថាម៉េដៃគេនិង
បានមួយក្រុមគ្នាខ្ញុំនិងបានគ្នាដប់ប្រាំបីរនាក់និងបានទាំងអស់គ្នា
ហើយគេទាត់មួយម្ភៃប្រាំបីរក្រុម ហើយជាប់មានតែក្រុមខ្ញុំនិងបានទាត់ជាប់ម៉េដៃនិង។

ក៖ ចាលោកពូ។

ខ៖ ហើយដល់តែពេលបានរំវាន់គឺមានសៀវភៅប្រាំក្បាល បិចប្រាំ
ហើយនិងខោអាវកូនសិស្សមួយកំភ្លេតែប៉ុននិងទេ កាលនិងខ្ញុំលេងឈ្នះនិងហាហាហា។

ក៖ ចាលោកពូចឹងខ្ញុំចង់សួលោកពូទៀតថាតើលោកពូចេះច្រៀងចំរៀងទេ?

ខ៖ ខ្ញុំអត់ចេះសោះ តាំងតែពីតូចរហូតដល់ប៉ុននិង ប៉ុន្តែខ្ញុំចូលចិត្តស្តាប់ចំរៀង។

ក៖ ចាលោកពូចូលចិត្តស្តាប់បទអី ?ហើយអ្នកចំរៀងឈ្មោះអី?

ខ៖ ខ្ញុំចូលចិត្តស្តាប់ជាងគេគឺស៊ុនស៊ីសាមុត និងរស់សិរីសោទ្ធា។

ក៖ ចាហើយអើ។

ខ៖ ខ្ញុំចូលចិត្តណាស់។

ក៖ ចា។

ខ៖ អោយតែបទសាមុត ខ្ញុំចូលចិត្តម៉ង
ហើយអាដែងសព្វថ្ងៃនិងអោយតែគេចាក់ក្រៅពីសាមុទអីនិងខ្ញុំថាហើយថ្លង់ណាស់។

ក៖ ចាហាហាហា។

ខ៖ ហើយតាំងតែពីអើយមកខ្ញុំចូលចិត្តស្តាប់តែគាត់ច្រៀងនិង។

ក៖
ចានិងហើយខ្ញុំធ្លាប់លឺម៉ាក់បាខ្ញុំអីគាត់ថាគាត់ចូលចិត្តស្តាប់តែបទស៊ុនស៊ីសាមុតពីដើមៗ
គឺចាស់ៗណាលោកពូ។

ខ៖ បាទ។

ក៖ បើបទអាឡូវនិងគឺមិនសូវទេ។

ខ៖ បាទដូចសព្វថ្ងៃអីនិងក៏ចឹងដែល បើសិនណាខ្ញុំមានទូរស័ព្ទប្រើ បើសិនណាខ្ញុំទៅប្រចូលអីខ្ញុំអោយគេដាក់បទសាមុតទាំងអស់និង ហាហាហា។

ក៖ ហាហាហាចា។ចឹងអើខ្ញុំចង់សួរលោកពូទៀតថានៅក្នុងក្រុមគ្រួសាររបស់លោកពូមានសមាជិតណាម្នាក់ដែលគាត់ចេះលេងឧបរកណ៍ភ្លេងខ្មែរ ឬក៏តន្ត្រីសម័យអីដែលឬទេលោកពូ?

ខ៖ អត់ អត់មានសោះ កូនចៅខ្ញុំអត់មានពីណាមានមួយចេះទេ តែបងប្អូនក៏អត់មាន អត់មានទេ បានតែប្អូនប្រុសមួយអាដែងធ្វើជាងដែករាល់ថ្ងៃនិង អានិងវាគ្រាន់ចេះច្រៀងចេះអី។ បើចំពោះតែខ្ញុំមួយនិងអត់សុទ្ធតែម្តង ក្រៅពីនិងអត់មានពីណាចេះអីទេ ដឹងតែពីរកស៊ីនិងពួកនិង បងប្អូនទាំងអស់និង។

ក៖ ហើយចឹងខ្ញុំចង់សួរលោកពូទៀតថា តើលោកពូមានផ្ទះដែលមានលក្ខណះយ៉ាងមេចដែលតាំងពីក្មេងរហូតមកដល់លោកពូធំណាស់?

ខ៖ កាលពីឪពុកម្តាយខ្ញុំនៅផ្ទះមានអី គួសមដែលដល់តែពេលបែកអាពតរហូតចឹងទៅគាត់ចេះតែពីបាកចិត្តលក់ចោលលក់អីទៅ រាល់ថ្ងៃនេះផ្ទះខ្ញុំនៅតែកូនខ្ទមមួយនិង នៅកូនខ្ទមមួយគ្រែតឲរាស់ថ្ងៃនិងនៅជាមួយកូន កូននិងនៅតែមួយគ្រែទេផ្ទះខ្ញុំរាល់ថ្ងៃនិង អានេះផ្ទះប្អូនជួលគេទេ ហាហាហា។

ក៖ ចាលោកពូ អរគុណលោកពូ។ ចឹងខ្ញុំចង់សួរលោកពូទៀតថាលោកពូចេះសាងសង់ផ្ទះដែលឬទេ?

ខ៖ ចេះដេលចេះ។

ក៖ ចាហើយលោកពូធ្លាប់សាងសង់ផ្ទះដែលអត់?

ខ៖ ធ្លាប់សាងសង់ដែលតាស់។

ក៖ ចាផ្ទះឈើ ឬក៏ផ្ទះថ្មរដែលលោកពូ។

ខ៖ ផ្ទះឈើក៏សង់បានផ្ទះថ្មរក៏សង់បានដែលអោយតែថាផ្ទះ។

ក៖ ចាហើយចុះលោកពូរៀនចេះអាចំណាញសាងសង់ផ្ទះនិងដោយវិធីណាដែល? មានអ្នកបង្រៀនឬក៏មេចដែលលោកពូ?

ខ៖ អត់មានអ្នកនេះទេ ព្រោះកាលដែលនេះនិងមានគ្រូម្នាក់ ឈ្មោះថាតាហោនិងគាត់បង្រៀនខ្ញុំធ្វើដស់តែពេលគាត់ គាត់ស្រលាញ់ខ្ញុំនិងគាត់បង្រៀនៗទល់តែខ្ញុំចេះហើយបានគាត់អោយខ្ញុំដើរកការងារធ្វើខ្លួនឯង និងលោកតាហោ ខ្ញុំអត់ភ្លេចគុណគាត់ទេ អានិងមេជាធំខ្ញុំហើយ គាត់បង្រៀនខ្ញុំអោយចេះទាំងអស់បើម៉ាគ្រឿងសំណាណង់និគាត់ចេះ គាត់បង្រៀនខ្ញុំអោយចេះទាំងអស់តែម្តងបាទ។

ក៖ ចាចឹងខ្ញុំចង់សួរលោកពូទៀតថា តើការសាងសង់ផ្ទះរបស់លោកពូតើលោកពូមានឧបរកណ៍អ្វីខ្លះដែលដើម្បីសាងសង់ផ្ទះចឹងណាលោកពូ?

ខ៖ អានិងផ្ទះអីគេ ផ្ទះថ្មរឬក៏ផ្ទះឈើ?

ក៖ ផ្ទះថ្មរ ផ្ទះឈើអីក៏បាន។

ខ៖ បើសាងសង់ផ្ទះថ្មរទល់តែវាមានដូជា ស្លាបព្រារៀបឥតអីចឹងទៅ មានស៊ីម៉ុងអីៗនិងសំរាប់ដែលយើងធ្វើដូចជាដែក ជាថ្មរកាល់ស៊ី អង់ដឺអីចឹងទៅ ហើយខ្សាច់អីចឹងទៅ អានិងយើងអាចសាងសង់បានហើយដូចអើយើងមុនទៅសាងសង់និងយើងត្រូវរៀបចំគ្រឹសវាសិនទៅ រៀបចំគ្រឹសនិងរួចយើងគ្រអោយវាមាំហើយបានយើងសាងសងបាន ហាហាហា។

ក៖ ចាអរគុណច្រើនលោកពូ។ ហើយចឹងខ្ញុំចង់សួរលោកពូទៀតថាតើមានពេលណាខ្លះដែលលោកពូលំបាកបំផុតនៅក្នុងជីវិតរបស់លោកពូណា? ហើយតើលោកពូឆ្លងកាត់កាលំបាកមួយនិងដោយរបៀបណា?

ខ៖ អររឿងរាវជីវិតដែលវាពីបាកនោះ គឺពេលដែលខ្ញុំអត់ធ្វើអីក៏ខ្ញុំធ្វើ បារល្វេរក៏ខ្ញុំបារ បារបង្គន់ក៏ខ្ញុំបារដែលធ្វើមេចអោយតែបានលុយមកអោយកូនខ្ញុំស៊ីចុកបុកទំពារគ្រប់គ្រាន់

ហើយនីងកូនទៅរៀនតែប៉ុននិង ធ្វើមេចក៏ដោយអោយតែបានលុយ
ធ្វើកម្មករលីសែងក៏ខ្ញុំធ្លាប់ ថាអីក៏ខ្ញុំធ្លាប់ដែលក្នុងមួយឆាកជីវិតនិង ធ្វើខ្ញុំកញ្ជាស់គេមេច
ក៏ខ្ញុំធ្លាប់អស់ហើយមួយឆាកជីវិតនិង ដល់តែកូនវាធំៗទៅវាដឹង
វាដឹងត្រង់ថាខ្ញុំដើរស៊ីឈ្នួលគេមេចអីមេចចឹងដល់តែពេលរួចទៅកូនវាដឹងវាថាប៉ាអើយលែ
ងធ្វើអីទៅប៉ានៅផ្ទះចុះ ទុកគ្រាន់កូនមើលបានយូតិចព្រោះប៉ាចាស់ហើយកូនៗវាផ្ដាំមក
បើគិតទៅកូនវាអង្វរហើយខ្ញុំក៏លែងបាន បានជាខ្ញុំនិងភ្អាកពីការងារទៅតែប៉ុននិង
ហើយណាមួយទៅកូនវាអាណិតយើងផង ហើយណាមួយទៅភ្នែកខ្ញុំនិងក៏វាងងឹតដែល
មិនដូចខ្ញុំនៅពីក្មេងទេ បើនៅពីក្មេងភ្នែកយើងភ្លឺទៅធ្វើអីក៏វាលឿនច្បាស់លាស់
ដល់តែពេលចាស់និងទឹមទឹមៗ យឺតណាស់មិនបានដូចនៅពីក្មេងទេបាទ។

កៈ ចាចឹងអរគុណច្រើនលោកពូសំរាប់បទពីសោធន៏នៅក្នុងជីវិតរបស់លោកពូ។
ចឹងទងអំពីបទពីសោធន៏ល្អៗវិញតើលោកពូមានបទពីសោធន៏អ្វីខ្លះដែលល្អៗនៅក្នុងជីវិតរ
បស់លោកពូណា?ដូចជាកូនសប្បាយចិត្តពេលកូនរៀបការឬអី?

ខៈ បាទខ្ញុំសប្បាយចិត្តដែលកូនវា។

កៈ ដើរតាមកន្លងធម៌។

ខៈ វាដើរតាមដើយកន្លងធម៌
ស្ដាប់តាមបណ្ដាំឪពុកម្ដាយដែលប្រាប់និងប្រដែលប្រណ្ដៅទៅ
កូនថាមិនបាច់ធ្វើបុណ្យអីអោយទេ
អោយតែកូនចេះស្ដាប់ពាក្យបណ្ដាំរបស់ឪពុកម្ដាយយើងនិងប្រដៅទៅវាដើរតាមកន្លងធម៌និ
ង ខ្ញុំអរជាងដែលកូនអោយលុយ
អោយកាកទៀតសព្វថ្ងៃនិងបានកូនដើរដោយកន្លងធម៌និង
រឿងលុយកូនអោយក៏អោយកូនមិនអោយទេក៏អត់ទៅខ្ញុំអត់ខឹងកូនទេ
ព្រោះបានកូនដើរកន្លងធម៌ហើយ ហើយកូននិងក៏បានដូចចិត្តទៀត
អង្វរតែឪពុកកុំអោយដើរលេងសើចអីសុំអោយតែឪពុកនិងដើរនៅផ្ទះគ្រាន់មើលការខុសត្រូ
វនៅក្នុងផ្ទះអីនិងទៅ។

កៈ កូនលោកពូចឹងលោកពូមានកូនដែលល្អៗ
ហើយខ្ញុំចង់សួរលោកពូទៀតថាពេលដែលលោកពូនៅពីក្មេងណា

តើលោកពូធ្លាប់មានក្ដីសង្ឃឹមអីខ្លះនៅពេលដែលលោកពូធំឡើងណា? ថាលោកពូចង់ធ្វើដូចជាគ្រូបង្រៀន ឬក៏គ្រូពេទ្យឬអីណាធ្លាប់មានដែលទេលោកពូ?

ខ៖ កូនខ្ញុំមែន?

ក៖ អតត់ទេគឺលោកពូនិង។

ខ៖ អរកាលដែលខ្ញុំនៅក្មេងនិង ខ្ញុំមិនបានជាធ្វើអីទេព្រោះកាលនិងខ្ញុំចង់ធ្វើការដែល ដល់ទេពេលវាពីបាកពេកវាពីបាកនៅក្នុងក្រុមគ្រួសារកាលនិងប្អូនៗខ្ញុំនៅតូចៗនិងដល់អាឡូវខ្ញុំចេះទៅរត់ពន់និងគេទៅ ទៅរត់ពន់ដល់ជុំវិញនុះ តាំងពីជុំរំណង់ម៉ែកណង់ម៉ាង សាយធូរ អូបីជាន់ ណាំម៉ែកណាំគាងអីគេនុះ ហើយខ្ញុំទៅដល់ឯបន្ទាយអពិល ភ្នំរីឆាត ចៃឆ្កែកន្លងឆ្ងាញ់ កាលនិងខ្ញុំដើរ ដើរគ្រប់កន្លែង។តាំងពីជុំរំចាស់ ជុំរំថ្មីរ គរខ្យង់ ស្វាលអីលអីៗនិងរត់ បើនិយាយទៅអ្នករត់ពន់កាលនិងរត់កាត់ម៉សីវមាំណាស់ ដើម្បីយកកំរៃមកចិញ្ចឹមបងប្អូន ដល់តែចឹងទៅខ្ញុំក៏មិនសូវជាបានរៀនចិតថ្លៃដែល ដល់តែពេលដែលមើលទៅអាដែងនេះគាត់បានរៀងធូរស្រាលហើយ បានជាខ្ញុំមកធ្វើជាទ័ព្វនិងមក ហាហាហា។

ក៖ ចាលោកពូ។ ចឹងអរគុណច្រើនលោកពូ ហើយចឹងខ្ញុំចង់សួរលោកពូទៀតថាបើសិនជាអើលោកពូអាចផ្ដាំផ្ញើប្រាប់អ្វីមួយទៅកាន់កូនចៅជំនាន់ក្រោយណា តើលោកពូនិងនិយាយអីខ្លះទៅកាន់ពួកគាត់? កូនចៅអីចឹងណា?

ខ៖ ខ្ញុំគ្រាន់ផ្ដាំថាកូនចៅអើយ កុំអោយនែកធ្វើដូចជាក្មេងហិតកៅអី កូនកុំទៅប៉ះពារអោយសោះ ទៅលួចទៅឆក់ភ្លន់គេអីកូនកុំ ធ្វើអាកុំរូនិងកូនអាក្រក់ណាស់ សង្គមគេស្អប់បំផុតហើយអ្នកដែលធ្វើអាក្រក់និងវាមិនដែលបាននៅសុខទេ។ អាដែងនេះនិងកូនធ្វើតែល្អទៅ កូនធ្វើអោយតែត្រឹមត្រូវរកស៊ីអោយវាសុចរឹកដូចប៉ាចឹងណា ចឹងហើយបានជាប៉ាមិនចេះខ្លាចគេទេ ហើយទោះបីយ៉ាងណាក៏ដោយទៅដល់ណាក៏មិនចេះស្លាប់ដែល ខ្ញុំទហេដល់ណាក៏មិនចេះស្លាប់ដែលដោះសារខ្ញុំត្រង់ មនុស្សសុចរឹកត្រង់មិនចេះបាត់បង់ទេ អ្នកនិងស្អប់មួយ មានមួយរយអ្នកដែលគេស្រលាញ់និងចាំជួយយើងដែល បានជាខ្ញុំនិងសព្វថ្ងៃនិងខ្ញុំដើរទៅណាក៏គេនេះដែលទទួលស្គាល់ដែល ខ្ញុំជាមនុស្សត្រង់ហើយស្លូតបូត ខ្ញុំមិនមានអីផ្ដាំផ្ញើទេ សុំផ្ដាំផ្ញើប្រាប់កូនចៅប៉ុននិង

ថាធ្វើអោយបានដូចជាពាក្យសំដីដែលខ្ញុំនិយាយប្រាប់និងទៅអត់ចេះខុសទេ
ទៅដល់ណាទីណាក៏បានដែល
ហាហាហាបាទអារឿងកូនចៅនិងបើបានលឺហើយកុំប្រព្រឹត្តទៅអាខាងសែបគប់គ្រឿងញៀ
ននិងកុំអោយសោះ ផ្ដាំហើយផ្ដាំទៀតខ្ញុំ កុំអោយវានេះវានាំអន្តរាយដល់ខ្លួនទេបាទ។

កៈ ចាចឹងអរគុណាច្រើនលោកពូ។
ចឹងជាឪកាសចុងក្រោយខ្ញុំសូមអរគុណាដល់លោកពូដែលបានជួបជាមួយនិងខ្ញុំហើយ
អើជួយអោយខ្ញុំធ្វើកិច្ចសំភាស៏លោកពូនៅក្នុងថ្ងៃនិង ចឹងអរគុណាច្រើនលោកពូ។

ខៈ បាទ។

កៈ ចឹងអើបន្ទាប់ពីមួយនិងហើយខ្ញុំអាចសុំថតរូបលោកពូមួយទុកផងដែល។